# មហាវាណិជជាតក




ព្រះសាស្ដាកាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធពួកពាណិជអ្នកក្រុងសាវត្ថី បានត្រាស់ព្រះធម្មទេសនានេះមានពាក្យថា **វាណិជា សមិតឹ កត្វា** ដូច្នេះជាដើម ។

បានឮថា ពួកពាណិជទាំងនោះកាលទៅដើម្បីលក់ដូរ បានថ្វាយមហាទានដល់ព្រះសាស្ដា ហើយតាំងនៅក្នុងសរណៈ និងសីល រួចទើបពោលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើ ពួកខ្ញុំព្រះអង្គជាអ្នកមិនមានរោគត្រឡប់មកវិញ ពួកខ្ញុំនឹងថ្វាយបង្គំព្រះបាទារបស់ព្រះអង្គម្ដងទៀត ដូច្នេះហើយ ក៏ចេញទៅដោយរទេះដែលមានប្រមាណ ៥០០ ហើយបានដល់ផ្លូវកន្ដារ កាលមិនបានពិចារណាផ្លូវ គេទាំងនោះក៏វង្វេង ជាអ្នកមិនមានទឹក និងអាហារ ត្រាច់ទៅក្នុងព្រៃ បានឃើញដើមជ្រៃមួយដើម ដែលមាននាគហួងហែង នាំគ្នាដោះរទេះ

ហើយអង្គុយនៅនឹងគល់ជ្រៃនោះ ។ ពួកគេឃើញស្លឹកជ្រៃខៀវស្រស់ ក្រាស់ស្និទ្ធជិតល្អ ហាក់បីដូចជាមានទឹកដក់នៅជាប់ខាងក្នុង និងឃើញមែក ហាក់ដូចជា បំពង់ដែលពេញដោយទឹក ទើបគិតថា ទឹកក្នុងដើមឈើនេះនឹងមានជាពិតប្រាកដ ហាក់ដូចជា កំពុងសញ្ចរ យើងនឹងកាត់មែកខាងកើតរបស់ដើមជ្រៃនេះ ដើម្បីនឹងបានទឹកផឹក ។

លំដាប់នោះ បុរសម្នាក់ក៏ឡើងលើដើមឈើ ហើយកាត់មែកជ្រៃនោះ ធារទឹកមានប្រមាណប៉ុនដើមត្នោតហូរចេញអំពីមែកនោះ ។ មនុស្សទាំងឡាយ នាំគ្នាងូត និងផឹក ក្នុងទីនោះឯង ហើយកាត់មែកដែលនៅទិសខាងត្បូង ភោជនដែលមានរសផ្សេងៗក៏បានចេញមកអំពីមែកនោះ ។ ពួកគេបរិភោគហើយ ក៏កាត់មែកនៅទិសខាងលិច ស្ត្រីដែលប្រដាប់ដោយគ្រឿងអលង្ការ ក៏ចេញមកអំពីមែកនោះ ។ ពួកអ្នកឈ្មួញនាំគាំអភិរម្យជាមួយនឹងស្ត្រីទាំងនោះ រួចទើបទៅកាត់មែកដែលនៅទិសខាងជើងទៀត រតនៈ ៧ ប្រការក៏ចេញអំពីមែកនោះ ។ ពួកពាណិជកាន់យករតនៈទាំងនោះ ដាក់ទុកក្នុងរទេះទាំង ៥០០ ឲ្យពេញ ហើយធ្វើដំណើរត្រឡប់ក្រោយ មកកាន់ក្រុងសាវត្ថីវិញ រក្សាទុកដាក់ទ្រព្យ រួចហើយជាអ្នកមានដៃកាន់គ្រឿងក្រអូប និងផ្កាកម្រងជាដើម នាំគ្នាទៅវត្តជេតពន ថ្វាយបង្គំព្រះសាស្ដា បូជាព្រះអង្គហើយអង្គុយក្នុងទីដ៏សមគួរ បានស្ដាប់ធម្មកថា រួចក៏ចេញទៅ ក្នុងថ្ងៃស្អែក បានថ្វាយមហាទាន និងឧទ្ទិសចំណែកទានដល់ទេវតាថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គសូមឲ្យចំណែកបុណ្យនៃទាននេះ ដល់រុក្ខទេវតាដែលជាអ្នកឲ្យទ្រព្យដល់ខ្ញុំព្រះអង្គ ។ ព្រះសាស្ដាកាលធ្វើភត្តកិច្ចចប់ហើយ ត្រាស់សួរថា ពួកអ្នកឲ្យចំណែកបុណ្យដល់រុក្ខទេវតាណា។ ពួកពាណិជបានប្រាប់អាការការបានទ្រព្យ ក្នុងដើមជ្រៃ ដល់ព្រះតថាគត ។ ព្រះសាស្ដាត្រាស់ថា ម្នាលអ្នកទាំងឡាយ ពួកអ្នកមិនលុះក្នុងអំណាចតណ្ហា ព្រោះជាអ្នកដឹងប្រមាណ ជាដំបូង ទើបបានទ្រព្យ ចំណែកពួកពាណិជក្នុងកាលមុន ជាអ្នកលុះក្នុងអំណាចតណ្ហា ព្រោះមិនដឹង

ប្រមាណ ទើបលះបង់ទ្រព្យនិងជីវិត ដូច្នេះហើយ ព្រះអង្គដែលត្រូវពួកពាណិជទូលអង្វរអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសម្តែងថា

ក្នុងអតីតកាល (រឿងរ៉ាវទាំងឡាយដូចគ្នាគឺ) ផ្លូវកន្តារ និងដើមជ្រៃនោះឯង តែអ្នកជំនួញនៅក្នុងនគរពារាណសី ។ ពួកពាណិជវង្វេងផ្លូវ ហើយបានឃើញដើមជ្រៃនោះឯង ។

ព្រះសាស្តាកាលបានត្រាស់ជាព្រះអភិសម្ពុទ្ធហើយ ទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ព្រះគាថាទាំងឡាយថា

វាណិជា សមិតិំ កត្វា, នានារដ្ឋតោ អាគតា;
ធនាហរា បក្កមិំសុ, ឯកំ កត្វាន គាមណិំ។

ពាណិជទាំងឡាយ ជាអ្នកស្វែងរកទ្រព្យ មកអំពីដែនផ្សេងៗ ធ្វើនូវការប្រជុំ (ក្នុងក្រុងពារាណសី) ធ្វើបុគ្គលម្នាក់ ឲ្យជាធំ ហើយចៀសចេញទៅ ។

តេ តំ កន្តារមាគម្ម, អប្បភក្ខំ អនោទកំ;
មហានិគ្រោធមទ្ទក្ខុំ, សីតច្ឆាយំ មនោរមំ។

ពាណិជទាំងឡាយនោះ មកដល់ផ្លូវឆ្ងាយដាច់ស្រយាលនោះ ជាផ្លូវមិនមានស្បៀងអាហារ មិនមានទឹក បានឃើញនូវដើមជ្រៃធំ មានម្លប់ត្រជាក់ជាទីរីករាយនៃចិត្ត ។

តេ ច តត្ថ និសីទិត្វា, តស្ស រុក្ខស្ស ឆាយយា;
វាណិជា សមចិន្តេសុំ, ពាលា មោហេន ចារុតា។

ឯពាណិជទាំងនោះ ជាបុគ្គលល្ងង់ ត្រូវមោហៈបិទបាំង ក៏អង្គុយក្រោមម្លប់ឈើនោះ ក្នុងទីនោះ ហើយប្រឹក្សាគ្នាថា

អល្លាយតេ អយំ រុក្ខោ, អបិ វារីវ សន្ទតិ;
ឥង្ឃស្សុ បុរិមំ សាខំ, មយំ ឆិន្ទាម វាណិជា។

*យីអើឈើនេះ ហាក់ដូចជាសើមដោយទឹក ហាក់ដូចជាមានទឹកហូរទៅ បើដូច្នោះ យើងជាពួកឈ្មួញនឹងកាប់នូវមែកឈើខាងកើត ។*

សា ច ឆិន្នាវ បគ្ឃរិ, អច្ឆំ វារឹ អនាវិលំ;
តេ តត្ថ ន្ហត្វា បិវិត្វា, យាវតិច្ឆឹសុ វាណិជា។

*សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាប់ដាច់ភ្លាម ក៏ស្រក់ទឹកចេញ ឯទឹកក៏ថ្លាមិនល្អក់ ពាណិជទាំងនោះបានងូតផឹកក្នុងទីនោះ ដរាបដល់អស់ចំណង់ ។*

ទុតិយំ សមចិន្តេសុំ, ពាលា មោហេន ចារុតា;
ឥង្ឃស្សុ ទក្ខិណំ សាខំ, មយំ ឆិន្ទាម វាណិជា។

*ពួកឈ្មួញពាល ត្រូវមោហៈបិទបាំង ប្រឹក្សានូវហេតុទី ២ ថា បើដូច្នោះ ពួកយើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងត្បូងនោះទៀត ។*

សា ច ឆិន្នាវ បគ្ឃរិ, សាលិមំសោទនំ ពហុំ;
អប្បោទវណ្ណេ កុម្មាសេ, សិង្គឹ វិទលសូបិយោ។

*សោតឯមែកឈើនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវបាយនៃ ស្រូវសាលី ដ៏លាយដោយសាច់ដ៏ច្រើន នូវនំកុម្មាស ហាក់ដូចជាបាយាសមានទឹកតិច នូវសម្លកកូរ និងសម្លសណ្តែកបាយ ។*

តេ តត្ថ ភុត្វា ខាទិត្វា, យាវតិច្ឆឹសុ វាណិជា;
តតិយំ សមចិន្តេសុំ, ពាលា មោហេន ចារុតា;

ភង្គស្ស បច្ឆិមំ សាខំ, មយំ ឆិន្ទាម វាណិជា។

ពាណិជទាំងនោះ បានបរិភោគទំពាស៊ីក្នុងទីនោះដរាបទាល់តែអស់ចំណង់ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សាគ្នានូវហេតុទី ៣ ថា បើដូច្នោះ យើងជាពួកឈ្មួញនឹងកាត់មែកឈើខាងលិចនោះទៀត ។

សា ច ឆិន្នាវ បគ្ឃរិ, នារិយោ សមលង្កតា;
វិចិត្រវត្ថាភរណា, អាមុត្តមណិកុណ្ឌលា។

សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ចេញនូវពួកនាងនារី មានខ្លួនតាក់តែងហើយ មានសំពត់សនិងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមណីនិងកុណ្ឌល ។

អបិ សុ វាណិជា ឯកា, នារិយោ បណ្ណវីសតិ;
សមន្តា បរិវារិំសុ, តស្ស រុក្ខស្ស ឆាយយា;
តេ តាហិ បរិចារេត្វា, យាវតិច្ឆិំសុ វាណិជា។

គួរសរសើរដែរ ពាណិជទាំងឡាយមាននាងនារីម្នាក់ៗ ចំណែកខាងនាងនារី ២៥ នាក់ បោមពោម (នូវនាយឈ្មួញជាធំ) ក្រោមម្លប់ឈើនោះដោយជុំវិញ ពាណិជទាំងនោះ ត្រូវនាងនារីទាំងនោះ បោមពោមហើយ ដរាបអស់ចំណង់ ។

ចតុត្ថំ សមចិន្តេសុំ, ពាលា មោហេន ចារុតា;
ភង្គស្ស ឧត្តរំ សាខំ, មយំ ឆិន្ទាម វាណិជា។

ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៤ ថា បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងជើងនោះទៀត ។

សា ច និដ្ឋាវ បត្ស៊ិ, មុត្តា វេឡុរិយា ពហូ;
រជតំ ជាតរូបញ្ច, កុត្តិយោ បដិយានិ ច។

*សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវកែវមុក្តានិងកែវពៃទូរ្យដ៏ច្រើនផង នូវប្រាក់ផង នូវមាសផង នូវកម្រាលសម្រាប់ក្រាលលើខ្នងដំរីជាដើមផង នូវកម្រាលរោមសត្វជាដើមផង ។*

កាសិកានិ ច វត្ថានិ, ឧទ្ទិយានិ ច កម្ពលា;
តេ តត្ថ ភារេ ពន្ធិត្វា, យាវតិច្ឆឹសុ វាណិជា។

*នូវសំពត់ដែលគេធ្វើក្នុងដែនកាសីផង នូវសំពត់កម្ពលឈ្មោះឧទ្ទិយាផង ពាណិជទាំងនោះ ក៏វេចយកនូវភារៈ ដរាបទាល់តែអស់ចំណង់ក្នុងទីនោះ។*

បញ្ញាមំ សមចិន្តេសុំ, ពាលា មោហេន ចារុតា;
ឥង្ឃស្ស មូលំ ឆិន្ទាម, អបិ ភិយ្យោ លភាមសេ។

*ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៥ បើដូច្នោះ ពួកយើងនឹងកាត់ត្រង់គល់ឈើនោះ មុខជានឹងបានច្រើនជាងនេះទៅទៀត ។*

អថុដ្ឋហិ សត្ថវាហោ, យាចមានោ កតញ្ជលី;
និគ្រោធោ កិំ បរជ្ឈតិ, វាណិជា ភទ្ទមត្ថុ តេ។

*គ្រានោះពួកឈ្មួញធំ ក្រោកឡើងផ្គងអញ្ជលីអង្វរថា ដើមជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចម្រើនចូរមានដល់អ្នកចុះ ។*

វារិទា បុរិមា សាខា, អន្នបានញ្ច ទក្ខិណា;
ជាវិទា បច្ឆិមា សាខា, សព្វកាមេ ច ឧត្តរា;

និគ្រោធោ តំ បវុច្ចតិ, វាណិជា ភទ្ទមត្ថុ តេ។

*មែកខាងកើតបានឲ្យទឹកផ្លូតផង មែកខាងត្បូង បានឲ្យបាយនិងទឹកផង មែកខាងលិច បានឲ្យនាងនារីទាំងឡាយផង មែកខាងជើង បានឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងផង ដើមជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចម្រើនចូរមានដល់អ្នកចុះ ។*

យស្ស រុក្ខស្ស ឆាយាយ, និសីទេយ្យ សយេយ្យ វា;
ន តស្ស សាខំ ភញ្ជេយ្យ, មិត្តទុព្ភោ ហិ បាបកោ។

*បុគ្គលអង្គុយឬដេក ក្រោមម្លប់នៃឈើណា មិនត្រូវកាច់បំបាក់មែកឈើនោះឡើយ ព្រោះថាបុគ្គលអ្នកប្រទូស្តមិត្ត ជាមនុស្សអាក្រក់ ។*

តេ ច តស្សានាទិយិត្វា, ឯកស្ស វចនំ ពហូ;
និសិតាហិ កុឋារីហិ, មូលតោ នំ ឧបក្កមុំ។

*ឯឈ្មួញទាំងនោះ ច្រើនគ្នាមិនអើពើនូវពាក្យនៃឈ្មួញ ជាធំម្នាក់ឯងនោះ ក៏ចូលទៅដើម្បីនឹងកាត់នូវដើមជ្រៃនោះត្រង់គល់ ដោយពូថៅទាំងឡាយ ដែលខ្លួនសំលៀងហើយ ។*

*គ្រានោះ នាគរាជឃើញពួកពាណិជដែលចូលមកជិតដើមជ្រៃដើម្បីនឹងកាប់នោះ គិតថា យើងបានឲ្យទឹកផឹកដល់ពួកពាណិជទាំងនោះដែលស្រេកទឹក បន្ទាប់មក បានបណ្តាលភោជនជាទិព្វឲ្យ រួចហើយបានឲ្យទីដេកជាដើម និងនារីជាបរិចារិកា បន្ទាប់ពីនោះ បានឲ្យនូវរតនៈដ៏ពេញដោយរទេះ ៥០០ តែឥឡូវនេះពួកនេះនិយាយគ្នាថា យើងនឹងកាត់ឫសគល់ដើមឈើ ពួកពាណិជទាំងនេះអាក្រក់ណាស់ យើងគួរនឹងសម្លាប់ពួកពាណិជឲ្យអស់ វៀរលែងតែប្រធាននោះចេញ ។ នាគរាជនោះចាត់ចែងពួកសេនាដោយដាក់បញ្ជាថា ទាហានពាក់អាវក្រោះប៉ុណ្ណោះចូរចេញទៅ ទាហានកាន់ធ្នូប៉ុណ្ណោះចូរចេញទៅ ទាហានកាន់ខែលប៉ុណ្ណោះចូរចេញទៅ ។*

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាថា*

**តតោ ជាតា និក្ខមឹសុ, សន្នទ្ធា បណ្ណវីសតិ;**
**ជនុគ្គហានំ តិសតា, ឆសហស្សា ច វម្មិនោ។**

***លំដាប់នោះ នាគទាំងឡាយ ២៥ សៀតគ្រឿងក្រោះហើយផង ពួកនាគខ្វាន់ធ្នូ ៣០០ ផង ពួកទាហានកាន់ខែលប្រាំមួយពាន់ផង ក៏ចេញមក ។***

*ពាក្យថា **សៀតគ្រឿងក្រោះ** សេចក្តីថាមានគ្រឿងក្រោះដែលប្រដាប់ដោយមាស និង ប្រាក់ជាដើម ។ ពាក្យថា **ពួកនាគខ្វាន់ធ្នូ ៣០០** សេចក្តីថា ពួកទាហានកាន់ធ្នូដែលធ្វើដោយ ស្នែងកែះ ៣០០ នាក់ ។ ពាក្យថា **ពួកទាហានកាន់ខែល** សេចក្តីថា ពួកទាហានដែលកាន់ ខែល ៦០០០ នាក់ ។*

**ឯតេ ហនថ ពន្ធថ, មា វោ មុញ្ចិត្ថ ជីវិតំ;**
**ឋបេត្វា សត្ថវាហំវ, សព្ពេ ករោថ ភេ។**

*(នាគរាជពោលថា)* ***អ្នកទាំងឡាយចូរសម្លាប់ ចូរចងនូវពាណិជទាំងនុ៎ះ អ្នកទាំងឡាយ កុំលែងនូវជីវិតឡើយ អ្នកទាំងឡាយចូរធ្វើនូវពួកពាណិជទាំងអស់នោះ ឲ្យទៅជាផេះ ទុកតែ ពាណិជជាធំម្នាក់ប៉ុណ្ណោះ ។***

*នេះជាគាថាដែលនាគរាជបានពោល ។*

*ពួកនាគក៏បានធ្វើយ៉ាងនោះ រួចហើយនាំគ្នាលើកគ្រឿងកម្រាលជាដើម ដាក់ក្នុងរទេះ ទាំង ៥០០ កាន់យកពាណិជជាប្រធាន ហើយបររទេះទាំងនោះទៅខ្លួនឯង រហូតដល់នគរ*

ពារាណសី និងជញ្ជូនទ្រព្យទាំងអស់ដាក់ទុកក្នុងផ្ទះរបស់ពាណិជនោះ ហើយជម្រាបលាពាណិជ ទៅកាន់ពិភពនាគរបស់ខ្លួនវិញ ។

ព្រះសាស្តាបានដឹងសេចក្តីនោះ ទើបត្រាស់គាថា ២ ដោយអំណាចនៃឱវាទថា

តស្មា ហិ បណ្ឌិតោ ចោសោ, សម្បស្សំ អត្ថមត្តនោ;
លោកស្ស ន វសំ គច្ឆេ, ហានេយ្យាវិសតំ មធំ។

ព្រោះហេតុនោះ បណ្ឌិតបុរស កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន មិនគប្បីលុះអំណាចនៃលោភៈឡើយ ត្រូវតែកម្ចាត់បង់នូវចិត្ត ដែលប្រកបដោយលោភៈប្រាកដដូច្នោះ ។

ឯវមាទីនវំ ញត្វា, តណ្ហា ទុក្ខស្ស សម្ភវំ;
វីតតណ្ហោ អនាទានោ, សតោ ភិក្ខុ បរិព្ពជេ។

ភិក្ខុបើបានដឹងនូវទោស (ក្នុងលោភៈ) យ៉ាងនេះ ដឹងនូវការកើតឡើងនៃទុក្ខ ព្រោះតណ្ហាយ៉ាងនេះហើយ គប្បីប្រព្រឹត្តជាអ្នកមានតណ្ហាទៅប្រាសហើយ មិនមានសេចក្តីប្រកាន់មាំ មានស្មារតី ។

ព្រះសាស្តាកាលនាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលឧបាសកទាំងឡាយ ពួកពាណិជដែលលុះក្នុងអំណាចនៃលោភៈក្នុងកាលមុន ដល់នូវសេចក្តីវិនាសធំ ព្រោះហេតុនោះ អ្នកទាំងឡាយមិនគប្បីជាអ្នកលុះក្នុងអំណាចនៃលោភៈឡើយ ដូច្នេះហើយព្រះអង្គប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ពួកពាណិជទាំងឡាយនោះក៏បានតាំងនៅក្នុងសោតាបត្តិផល ។

**តទា ជាតរាជា សារិបុត្តោ អហោសិ** នាគរាជក្នុងកាលនោះ បានមកជាសារីបុត្រ **សត្ថវាហោ បន អហមេវ អហោសិំ** ចំណែកពាណិជជាប្រធាន គឺតថាគតនេះ ឯង ។

*ចប់ មហាវាណិជជាតក ៕*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដកលេខ ៦០ ទំព័រ ៤០ )*

*ថ្ងៃពុធ ៩ កើត ខែជេស្ឋ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៣ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*